# សុន្ទរកថា
# ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
# ក្នុងពិធីសម្ពោធ និងផ្សព្វផ្សាយឯកសារគោលនយោបាយរបស់ CAMFEBA
# ស្តីពី មាគ៌ាឆ្ពោះទៅកាន់ភាពរុងរឿង និងរបាយការណ៍របស់អង្គការអន្តរជាតិខាងការងារ
# ស្តីពី "បរិយាកាសអំណោយផលដើម្បីធ្វើឲ្យសហគ្រាសមានចិរភាព
# ក្នុងព្រះរាជាណាចក្រកម្ពុជា"
# ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤

-សូមគោរពគណៈអធិបតី

-ឯកឧត្តម លោកជំទាវ តំណាងស្ថានទូត ស្ថានកុងស៊ុលនៃបណ្តាប្រទេសជាមិត្ត

-ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ជាទីរាប់អាន !

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្ស និងសប្បាយរីករាយជាពន្លឹកដោយបានចូលរួមក្នុងពិធីក្នុងពិធីសម្ពោធ និងផ្សព្វផ្សាយឯកសារគោលនយោបាយរបស់សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) ស្តីពីមាគ៌ាឆ្ពោះទៅកាន់ភាពរុងរឿង និងរបាយការណ៍របស់អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពី "បរិយាកាសអំណោយផលដើម្បីធ្វើឲ្យសហគ្រាសមានចិរភាពក្នុងព្រះរាជាណាចក្រកម្ពុជា" ។

ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាអញ្ជើញចូលរួមក្នុងពិធីសម្ពោធ និងផ្សព្វផ្សាយឯកសារគោលនយោបាយ និងរបាយការណ៍ ដែលរៀបចំឡើងក្រោមកិច្ចសហការរវាង CAMFEBA និងអង្គការ ILO នាពេលនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ (ILO) និងCAMFEBA ដែលបានខិតខំប្រឹងប្រែងធ្វើការសិក្សាស្រាវជ្រាវ និងបានបោះពុម្ពចេញជារបាយការណ៍ស្តីពីមាគ៌ាឆ្ពោះទៅកាន់ភាពរុងរឿង និងរបាយការណ៍ស្តីពីបរិយាកាសអំណោយផលដើម្បីធ្វើឲ្យសហគ្រាសមានចិរភាព សម្រាប់ផ្សព្វផ្សាយដល់ដៃគូពាក់ព័ន្ធទាំងអស់ឲ្យបានយល់ដឹង និងចូលរួមអនុវត្តអនុសាសន៍នានា ក្នុងគោលដៅធ្វើឲ្យកម្ពុជាមានកំណើនសេដ្ឋកិច្ច និងសហគ្រាសមានចិរភាព។ ខ្ញុំសង្កេតឃើញថា របាយការណ៍ បានផ្តោតលើបួនចំនុចសំខាន់គឺ ទី១-ការបង្កើតជំនាញដើម្បីប្រកួតប្រជែង ទី២-ការធ្វើឲ្យទំនាក់ទំនងនៅកន្លែងធ្វើការកាន់តែប្រសើរ ទី៣-ការកសាងបទដ្ឋានច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដើម្បីផ្តល់ទំនុកចិត្តជូនអ្នកវិនិយោគ និងទី៤-អភិបាលកិច្ចល្អដើម្បីកំណើន។

រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណ និងចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានការគិតគូរវែងឆ្ងាយ និងល្អិតល្អន់ ជាពិសេសធានាអនាគតប្រកបដោយវិបុលភាពរបស់កម្ពុជា និងប្រជាជនកម្ពុជាទាំងមូល។ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា ក្នុងនោះ ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលគឺការកសាងសង្គមមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌ ការកែលម្អជីវភាព ការបង្កើត និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ល។

កម្ពុជាគឺជាប្រទេសដែលមានសក្តានុពលមួយខាងកម្លាំងពលកម្មការងារ ដោយសារប្រជាជនកម្ពុជា ៣២ ភាគរយមានអាយុក្រោម ១៥ ឆ្នាំ ហើយមានយុវជនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ ឈានចូលក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ។ រាជរដ្ឋាភិបាល តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតគម្រោងពង្រឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលអាចជួយសម្រួលការធ្វើសមាហរណកម្មយុវជនទៅក្នុងទីផ្សារការងារ តាមរយៈការបង្កើតជំនាញអនុវត្តជាក់ស្តែង ហើយទន្ទឹមនឹងនេះក៏ជួយផ្តល់នូវជម្រើសផ្សេងៗដល់សិស្សនិស្សិតក្រៅពីការអប់រំនៅសាលាចំណេះទូទៅឲ្យមានលក្ខណៈសម្បត្តិសមស្រប ដើម្បីទទួលបានការងារ។ អត្ថប្រយោជន៍ជាវិជ្ជមានបានកើតមានយ៉ាងច្រើនដោយសារចំនួនសិស្សបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជា បានកើនឡើងពី៨៨.៣៦៧នាក់ ក្នុងឆ្នាំ២០០៧ ដល់១១៣.៦៤៨នាក់ ក្នុងឆ្នាំ២០០៨។

ក្នុងផ្នែកទំនាក់ទំនងវិជ្ជាជីវៈ កន្លងមករាជរដ្ឋាភិបាលបានបង្កើតនូវស្ថាប័នត្រីភាគីជាច្រើនដែលមានការចូលរួមពីភាគីសហជីព ភាគីនិយោជក និងតំណាងរាជរដ្ឋាភិបាលដើម្បីពិគ្រោះយោបល់ និងសម្រេចលើការងារសំខាន់ៗទាក់ទងនឹងបញ្ហាទំនាក់ទំនងវិជ្ជាជីវៈ ដូចជាគណៈកម្មការប្រឹក្សាការងារ ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈជាដើម។ល។ ដើម្បីដោះស្រាយវិវាទរួមអំពីសិទ្ធិ និងផលប្រយោជន៍ ដែលគ្រប់ភាគីទាំងអស់អាចទទួលយកបាន ។ ម្យ៉ាងវិញទៀត នាយកដ្ឋានដោះស្រាយវិវាទការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានដើរតួនាទីយ៉ាងសំខាន់មួយចំពោះការដោះស្រាយរាល់បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ ហើយប្រសិទ្ធិភាពការងាររបស់នាយកដ្ឋានបានរីកចំរើនកាន់តែប្រសើរឡើង។ បន្ថែមពីនេះទៀត នាយកដ្ឋានក៏ទទួលបន្ទុកក្នុងការចុះបញ្ជីសហជីព និងបញ្ជាក់ពី "ភាពជាតំណាង" និង"ភាពជាតំណាងបំផុត" របស់សហជីពផងដែរ។ រាជរដ្ឋាភិបាលបាននិងកំពុងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីសហជីព ហើយដែលសង្ឃឹមថា

និងអនុម័តឲ្យអនុវត្តនៅចុងឆ្នាំ២០១៤ខាងមុខនេះ។ អនុស្សារណៈយោគយល់គ្នាស្ដីពីការលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងវិស័យកាត់ដេរ (MoU) ដែលបានចុះហត្ថលេខាក្នុងខែកញ្ញា ឆ្នាំ២០១០ រវាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសហជីពជាច្រើន ហើយបន្តជាថ្មីក្នុងឆ្នាំ ២០១៣ ត្រូវការការអនុវត្តឲ្យបានតឹងរ៉ឹង និងទាន់ពេលវេលា។ ក្នុងអនុស្សារណៈនេះ ភាគីទាំងពីរបានព្រមព្រៀងប្រើប្រាស់នីតិវិធីមជ្ឈត្តកម្មចងកាតព្វកិច្ចរបស់ LAC ចំពោះវិវាទអំពីសិទ្ធិ ការល្មើសច្បាប់ និងអនុសញ្ញារួមដែលមានស្រាប់។ ទោះជាយ៉ាងណា យើងទទួលស្គាល់ថា កិច្ចសន្ទនាសង្គមពិតប្រាកដមិនចប់ត្រឹមចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះទេ ប៉ុន្តែត្រូវពឹងផ្អែកលើការអនុវត្តយ៉ាងពេញលេញ ហើយវឌ្ឍនភាពនៅត្រង់ចំនុចនេះ នៅមានភាពយឺតយ៉ាវនៅឡើយ។

ច្បាប់ និងបទប្បញ្ញត្តិដែលរៀបចំឡើងល្អ បង្កើតបាននូវក្របខណ្ឌមួយដើម្បីពង្រឹងការប្រកួតប្រជែង ធ្វើឲ្យសេដ្ឋកិច្ចទទួលបានជោគជ័យ និងកាត់បន្ថយបាននូវចំណាយក្រៅផ្លូវការ បង្កើនប្រសិទ្ធិភាព និងជំរុញឲ្យមានគំនិតច្នៃប្រឌិតថ្មីៗទៀត ដើម្បីកម្ពុជាអាចធ្វើសមាហរណកម្មសេដ្ឋកិច្ចជាមួយនឹងប្រទេសជិតខាងក្នុងអាស៊ាននាពេលខាងមុខ ដែលជាគោលដៅមានសារៈសំខាន់ចំពោះអនាគតប្រទេស។

ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ភាពតានតឹងក្នុងបរិយាកាសនៃទំនាក់ទំនងវិជ្ជាជីវៈបានរាំងដល់ការវិនិយោគ និងធ្វើឲ្យប៉ះពាល់ដល់កេរ្ដិ៍ឈ្មោះនៃការគោរពតាមបទដ្ឋានការងារជាតិ និងអន្តរជាតិនៅក្នុងវិស័យកាត់ដេរ។ ភាពចលាចលនៃទំនាក់ទំនងនៅកន្លែងធ្វើការ ដែលបានកើតមានច្រើនក្នុងឆ្នាំ ២០១៣ និងចូលដល់ឆ្នាំ ២០១៤ នោះ គូសបញ្ជាក់នូវភាពចាំបាច់ដែលត្រូវរៀបចំប្រព័ន្ធកិច្ចសន្ទនាសង្គម និងទំនាក់ទំនងវិជ្ជាជីវៈនៅកន្លែងធ្វើការដ៏ក្មេងខ្ចីរបស់យើងឲ្យប្រសើរឡើងវិញ។

កម្ពុជាក៏មានវឌ្ឍនភាពក្នុងការលើកកម្ពស់សុខភាព និងសុវត្ថិភាពរបស់កម្មករផងដែរ។ ក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិរបបជាតិសន្តិសុខសង្គម(NSSF) ហើយនិយោជកមានកាតព្វកិច្ចត្រូវចូលរួមចាប់ពីឆ្នាំ ២០០៨ មក។ គិតមកត្រឹមខែមករា ឆ្នាំ ២០១៤ មានសហគ្រាសជាង ៤០០០ បានចុះបញ្ជីនៅ NSSF។ កំណែទម្រង់នាពេលខាងមុខ នឹងធ្វើឲ្យគម្រោងនេះខិតកាន់តែជិតដូចកម្មវិធីដែលអនុវត្តក្នុងប្រទេសដទៃទៀត ដែលប្រមូលប្រាក់រួមចំណែកពីនិយោជិត និងផ្ដល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារផង និងអត្ថប្រយោជន៍វេជ្ជសាស្ត្រទូទៅ និងប្រាក់សោធននិវត្តន៍ផង។ រាជរដ្ឋាភិបាលទទួលស្គាល់តួនាទីសំខាន់របស់ CAMFEBA ក្នុង NSSF មានសារៈសំខាន់ចំពោះភាពជោគជ័យនៃកម្មវិធីនេះ ហើយគួរចាត់ទុកជាគំរូសម្រាប់ការបញ្ចូលទស្សនៈនៃវិស័យឯកជននៅក្នុងដំណើរការរៀបចំគោលនយោបាយផ្សេងៗទៀត។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការច្បាស់លាស់ដើម្បីលើកកម្ពស់អភិបាលកិច្ច និងធ្វើឲ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ល្អប្រសើរឡើងនៅក្នុងរបាយការណ៍សកលលោកស្តីពីភាពប្រកួតប្រជែងហើយការស្រាវជ្រាវដោយអង្គការតម្លាភាពអន្តរជាតិ បង្ហាញនូវទំនុកចិត្តយ៉ាងពិតប្រាកដលើប្រសិទ្ធិភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ ដើម្បីបង្កើតនីតិវិធីរូមនិងងាយស្រួល សម្រាប់សេវាកម្មជាច្រើន។ ក្រសួងរបស់រាជរដ្ឋាភិបាលជាច្រើនបច្ចុប្បន្ននេះបានផ្សព្វផ្សាយកម្រៃសេវាកម្មផ្លូវការ។ ច្បាប់ និងស្ថាប័នជាច្រើនបានបង្កើតឡើងនៅកម្ពុជា ដើម្បីជួយកាត់បន្ថយនិងទប់ស្កាត់អំពើពុករលួយក្នុងជួររាជរដ្ឋាភិបាល។ ការបង្កើតច្បាប់ប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ ជាការបង្កើតយ៉ាងសំខាន់ក្នុងចំណោមស្ថាប័ននិងច្បាប់ដទៃទៀត។ ច្បាប់ប្រឆាំងអំពើពុករលួយកំណត់ទណ្ឌកម្មលើអ្នកទទួល និងអ្នកបង់កម្រៃសម្រួលហើយតម្រូវឲ្យមន្ត្រីរាជរដ្ឋាភិបាលប្រកាសទ្រព្យសម្បត្តិរៀងរាល់ពីឆ្នាំម្តង។ ស្ថាប័នពីរផ្សេងទៀត គឺអាជ្ញាធរសវនកម្មជាតិ និងមជ្ឈមណ្ឌលជាតិមជ្ឈត្តកម្ម ត្រូវបានបង្កើតឡើងដើម្បីជួយឲ្យមានដំណើរការល្អ និងទំនុកចិត្តលើរដ្ឋាភិបាលតាមរបៀបពីរខុសគ្នា។ ក្នុងឆ្នាំ២០០២ រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរសវនកម្មជាតិទទួលបន្ទុកធ្វើសវនកម្មពីខាងក្រៅលើទីភ្នាក់ងាររដ្ឋាភិបាល និងកសាងស្ថាប័នសវនកម្មកំពូល។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលជាតិមជ្ឈត្តកម្មគឺជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទី១របស់កម្ពុជា។ ដោយមានមជ្ឈមណ្ឌលជាតិមជ្ឈត្តកម្ម ក្រុមហ៊ុនអាចដោះស្រាយវិវាទពាណិជ្ជកម្ម បានកាន់តែឆាប់រហ័សនិងចំណាយតិចជាងប្រព័ន្ធតុលាការ ដោយកសាងទំនុកចិត្តថា វិធាននឹងត្រូវយកមកអនុវត្ត និងផ្តល់សន្តិសុខនិងស្ថិរភាពដែលក្រុមហ៊ុនពាណិជ្ជកម្មត្រូវការដើម្បីធ្វើការវិនិយោគ។

*ឯកឧត្តមលោកជំទាវលោក លោកស្រីនិងបងប្អូនទាំងអស់ !*

ទោះបីជាមានសមិទ្ធិផលយ៉ាងច្រើនក្រោមកិច្ចខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាល ដោយមានការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ វិស័យឯកជន និងបងប្អូនកម្មករនិយោជិតក៏ដោយ ក៏បញ្ហាចម្បងជាច្រើនក៏កំពុងប្រឈម ដែលទាមទារឲ្យយើងរួមសហការគ្នាដោះស្រាយបន្តទៀត ដូចជាបញ្ហាកង្វះជំនាញកំពុងប៉ះពាល់ជាអវិជ្ជមានលើការរីកចម្រើនរបស់ក្រុមហ៊ុន និងសេដ្ឋកិច្ចជាតិ។ ការងារដែលសេដ្ឋកិច្ចរបស់យើងបានបង្កើត ចាំបាច់ត្រូវបំពេញដោយប្រជាជនកម្ពុជា ប៉ុន្តែក្រុមហ៊ុនអាចរកកម្មករក្នុងស្រុកបានតែនៅក្នុងឧស្សាហកម្មធុនស្រាលប៉ុណ្ណោះ ហើយតំណែងដែលត្រូវការជំនាញកាន់តែខ្ពស់ជារៀយៗ ត្រូវបានកាន់កាប់ដោយបុគ្គលិកបរទេស។ ការដោះស្រាយបញ្ហានេះមានសារៈសំខាន់ ជាពិសេស បើគិតអំពីការធ្វើសមាហរណកម្មអាស៊ានបន្ថែមទៀតនោះយើងព្រួយបារម្ភអំពីលំហូរចូលដោយសេរីនៃកម្មករជំនាញ ទូទាំងតំបន់អាស៊ានដែលធ្វើ

ឲ្យកម្មករនិយោជិតរបស់យើងពិបាកក្នុងការប្រកួតប្រជែង។ យើងជឿជាក់ថាយើងអាចអភិវឌ្ឍជំនាញរបស់យុវជន និងកម្មករនិយោជិតថ្មីៗរបស់យើងបានយ៉ាងសកម្ម ដើម្បីបំពាក់បំប៉នពួកគេឲ្យចាប់យកឱកាសការងារថ្ងៃអនាគត។ ការធ្វើបែបនេះនឹងនាំទៅរកភាពរុងរឿងកាន់តែប្រសើរសម្រាប់បុគ្គល និងចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជាទាំងមូល។ ដើម្បីសម្រេចកិច្ចការនេះបាន យើងត្រូវមានប្រព័ន្ធអប់រំរឹងមាំ ផ្អែកលើទិន្នន័យច្បាស់លាស់ ដែលផ្សារភ្ជាប់យ៉ាងជិតស្និតទៅនឹងសេចក្តីត្រូវការកំពុងផ្លាស់ប្តូរនៃវិស័យឯកជន។ ដើម្បីដោះស្រាយគម្លាតនៃជំនាញនាពេលបច្ចុប្បន្ន យើងត្រូវមានការវិភាគដែលមានលក្ខណៈជាប្រព័ន្ធលើនិន្នាការការងារ និងការព្យាករណ៍។ យើងអាចសម្រេចបាននូវក្របខណ្ឌសម្រាប់ប្រមូលទិន្នន័យ ដើម្បីធ្វើការព្យាករណ៍អំពីជំនាញ ផ្គូផ្គងអ្នកស្វែងរកការងារធ្វើជាមួយនិងនិយោជក ព្រមទាំងបង្កើតប្រព័ន្ធអប់រំដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការដែលកំពុងវិវត្តន៍នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស តាមរយៈភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន។ កម្មវិធីបណ្តុះបណ្តាលរបស់យើងបន្តផ្លាស់ប្តូរដោយផ្អែកលើទិន្នន័យសេដ្ឋកិច្ចត្រឹមត្រូវនិងនាពេលបច្ចុប្បន្ន ហើយកម្លាំងពលកម្ម គឺជាធាតុផ្សំមួយយ៉ាងសំខាន់ ក្នុងការបង្កើនកម្លាំងពលកម្មផ្អែកលើតម្រូវការចេញពីប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល។ ផែនការមេផ្នែកស្ថិតិរយៈពេល១០ឆ្នាំសម្រាប់កម្ពុជា បានបង្កើតវិធីឆ្ពោះទៅបង្កើនសមត្ថភាពខាងផ្នែកស្ថិតិរបស់រាជរដ្ឋាភិបាល ដើម្បីជួយឲ្យរាជរដ្ឋាភិបាលបំពេញមុខងារកាន់តែប្រសើរឡើងក្នុងវិស័យជាច្រើន។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តពង្រឹងធ្វើពិពកម្ម និងពង្រីកប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលរបស់ខ្លួនបន្ថែមទៀត។ ការបន្តធ្វើបច្ចុប្បន្នភាពនិងកំណែទម្រង់ប្រព័ន្ធអប់រំរបស់យើង ផ្អែកលើទិន្នន័យត្រឹមត្រូវ គឺជាការចាំបាច់ដើម្បីធានាថាជំនាញចេញពីប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបំពេញបាននូវសេចក្តីត្រូវការក្នុងផ្នែកសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរ។ ដើម្បីទទួលបាននូវភាពជោគជ័យនេះ យើងត្រូវបន្តកែលំអរប្រព័ន្ធអប់រំនិងបណ្តុះបណ្តាល ហើយទាមទារការចូលរួមក្នុងភាពជាដៃគូពីដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន ជាពិសេសស CAMFEBA ក្នុងការធ្វើសកម្មភាពបន្តគាំទ្ររាជរដ្ឋាភិបាលក្នុងសកម្មភាពទាំងនេះ។

ទោះបីជាមានវេទិកាសម្រាប់កិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងឯកជន និងស្ថាប័ននិយ័តកម្មការងារត្រីភាគីក៏ដោយ ក៏ប៉ុន្តែកូដកម្ម នៅតែកើតឡើងជាញឹកញាប់ ហើយភាគច្រើនគឺធ្វើខុសច្បាប់។ កូដកម្មទាំងនេះពុំពិចារណាអំពីក្តីកង្វល់របស់កម្មករនិយោជិតទាំងមូលនោះទេ ប៉ុន្តែធ្វើឡើងដើម្បីគោលបំណងរបស់ក្រុមឱកាសនិយមមួយចំនួន ដែលប្រើប្រាស់ឱកាសធ្វើកូដកម្ម ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនគិតអំពីសេចក្តីត្រូវការរបស់កម្មកររោងចក្រទាំងមូលទេ។ ស្ទើរគ្រប់កូដកម្មទាំងអស់ពុំបានអនុវត្តតាមនីតិវិធីច្បាប់ ពោលគឺត្រូវរំលងកាត់ការផ្សះផ្សា និងមជ្ឈត្តកម្មបន្ទាប់ពីមកការអនុម័តដោយសម្លេងភាគច្រើនថាធ្វើកូដកម្ម និងចេញសេចក្តីជូនដំណឹងប្រាប់និយោ

ជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ម្យ៉ាងទៀត មានករណីបាតុកម្មបិទផ្លូវ ការរាំងខ្ទប់ច្រកចូលក្រុមហ៊ុន បង្ខំកម្មករឲ្យឈប់ធ្វើការងារចូលរួមបាតុកម្មជាមួយក្រុមខ្លួន ធ្វើឲ្យបង្អាក់ប្រតិបត្តិការពាណិជ្ជកម្មប្រចាំថ្ងៃ ដែលប៉ះពាល់មិនត្រឹមតែក្រុមហ៊ុន ឬវិស័យកាត់ដេរនោះទេ ប៉ុន្តែបានប៉ះពាល់ដល់សង្គមថែមទៀត ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ យើងត្រូវមានកិច្ចពិភាក្សាស្មោះត្រង់អំពីស្ថានការណ៍បច្ចុប្បន្ន និងឆន្ទៈសម្របសម្រួល និងការសន្យាគោរពតាមការព្រមព្រៀង។ ខ្ញុំសូមកោតសរសើរដល់អង្គការ ILO ដែលក្នុងរយៈពេល ១២ ឆ្នាំកន្លងមកនេះ បានចូលរួមយ៉ាងខ្លាំងជាមួយនឹងនិយោជក សហជីព និងរាជរដ្ឋាភិបាលដើម្បីធ្វើឲ្យប្រសើរឡើងនូវកិច្ចសន្ទនាសង្គម។ កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) របស់ ILO បានសម្រួលឲ្យមានការទទួលស្គាល់ជាសកលលើលក្ខខណ្ឌការងារល្អប្រសើរ និងប្រាក់ឈ្នួលខ្ពស់ដែលវិស័យកាត់ដេរ និងស្បែកជើងរបស់យើងបានផ្តល់ជូនកម្មករ។ បន្ទាប់ពីកិច្ចពិភាក្សាត្រីភាគីរវាងវិស័យឯកជន រាជរដ្ឋាភិបាល និងសហជីព ភាគីទាំងអស់បានព្រមព្រៀងតំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មកររោងចក្រកាត់ដេរ ប៉ុន្តែ សហជីពមួយចំនួនមិនគោរពលទ្ធផលនៃការចចារ បង្កកូដកម្មហិង្សា ដែលបាននាំឲ្យមនុស្សស្លាប់បាត់បង់ជីវិត និងរងរបួស។ ចំនុចសំខាន់គឺ ទាំងភាគីនិយោជក និងកម្មករនិយោជិតត្រូវយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ថែមទាំងការទទួលខុសត្រូវរបស់ខ្លួនក្នុងការគោរពតាមការព្រមព្រៀង និងធ្វើសកម្មភាពក្នុងរង្វង់ច្បាប់។ សហជីពភាគតិច គឺជាបញ្ហាប្រឈមដ៏ធំចំពោះការធានាឲ្យមានចលនាសហជីពរួមគ្នា និងរួមគ្នាទទួលខុសត្រូវ ដែលអាចចូលរួមចំណែកប្រកបដោយប្រសិទ្ធិភាពក្នុងក្របខណ្ឌត្រីភាគី។ ភាគីទាំងអស់ត្រូវតែគោរពសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន ក៏ដូចជាសិទ្ធិ និងការទទួលខុសត្រូវរបស់សមភាគី ហើយទទួលយកថា ដំណើរការសហការនេះគឺពាក់ព័ន្ធនឹងការសម្រុះសម្រួលគ្នា។ យើងចាំបាច់ត្រូវលើកកម្ពស់ និងកសាងកិច្ចសន្ទនារវាងដៃគូសង្គម ហើយបង្កើតទំនាក់ទំនងផ្អែកលើសេចក្តីសុចរិត និងការជឿទុកចិត្តគ្នា។ កិច្ចការនេះអាចសម្រេចបាន តាមរយៈការផ្តោតជាចម្បងលើបញ្ហាឯកភាពរួម និងខិតខំស្វែងរកនូវដំណោះស្រាយបែបស្ថាបនាចំពោះបញ្ហាខ្វែងគំនិតគ្នា។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបរាល់បាតុភាពនានារបស់ក្រុមជនឱកាសនិយមមួយចំនួន ដើម្បីការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

រាជរដ្ឋាភិបាល នឹងបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកសាងប្រព័ន្ធច្បាប់ និងលើកទឹកចិត្តឲ្យពាណិជ្ជកម្មចូលមកក្នុងប្រព័ន្ធកាន់តែច្រើនឡើងថែមទៀត។ច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលការពារប្រជាជនយើង មានសារៈសំខាន់ដើម្បីរក្សាសង្គមឲ្យមានយុត្តិធម៌ និងចុះសម្រុងគ្នា។ រាជរដ្ឋាភិបាលនឹងបន្តពិនិត្យ និងកែសម្រួលលើច្បាប់ស្តីពីការងារ ដើម្បីឲ្យស្របតាមភាពពិតជាក់ស្តែងខាងសេដ្ឋកិច្ចព្រមទាំងការសម្រួលការអភិវឌ្ឍ និងការលូតលាស់នៃពាណិជ្ជ

កម្ម ការការពារប្រកបដោយប្រសិទ្ធិភាពចំពោះការវិនិយោគ ទ្រព្យសម្បត្តិរូបវន្ត និងកម្មសិទ្ធិបញ្ញាបន្ថែមទៀត។ ប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិល្អមានសារៈសំខាន់ ក្នុងការសម្រេចបាននូវគោលដៅដែលកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនរបស់កម្ពុជា ហើយក្នុងការសម្រេចគោលដៅទាំងនេះ ជាការសំខាន់ដែលច្បាប់គាំទ្រគ្រប់សកម្មភាពទាំងអស់ក្នុងការធ្វើពាណិជ្ជកម្ម រាប់ទាំងការបង្កើត និងការចុះបញ្ជីពាណិជ្ជកម្ម ប្រតិបត្តិការប្រចាំថ្ងៃ ការគាំពារវិនិយោគ និងការដោះស្រាយវិវាទ។

ប្រព័ន្ធរដ្ឋបាល និងតុលាការយុត្តិធម៌ផ្តល់លទ្ធភាពដល់វិស័យឯកជនដំណើរការប្រកបដោយប្រសិទ្ធិភាព និងជឿទុកចិត្តពីអ្នកវិនិយោគ។ ស្ថិរភាពនិងភាពអាចព្យាករណ៍បានដែលនាំមកដោយអភិបាលកិច្ចកាន់តែល្អប្រសើរ នឹងមានអត្ថប្រយោជន៍ទូលំទូលាយចំពោះសេដ្ឋកិច្ចរបស់យើង។ រាជរដ្ឋាភិបាលបាននិងកំពុងការអភិវឌ្ឍប្រទេសកម្ពុជា ដោយត្រូវបានពន្លឿនតាមរយៈប្រព័ន្ធអភិបាលកិច្ចអេឡិចត្រូនិក ដែលជានីតិវិធីមានតម្លាភាព និងការផ្តល់កិច្ចការពារផ្លូវច្បាប់ចំពោះជនទាំងឡាយដែលរាយការណ៍ពីអំពើខុសច្បាប់ទាំងអស់។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមអំពាវនាវដល់គ្រប់ស្ថាប័នជាតិទាំងអស់ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ វិស័យឯកជន ព្រមទាំងបងប្អូនកម្មករនិយោជិត សហាជីព យកចិត្តទុកដាក់លើទិន្នន័យ និងអនុសាសន៍ដែលបានលើកឡើងនៅក្នុងឯកសារគោលនយោបាយរបស់ CAMFEBA ស្តីពី មាគ៌ាឆ្ពោះទៅកាន់ភាពរុងរឿង និងរបាយការណ៍របស់អង្គការអន្តរជាតិខាងការងារ ស្តីពី"បរិយាកាសអំណោយផលដើម្បីធ្វើឲ្យសហគ្រាសមានចិរភាពក្នុងព្រះរាជាណាចក្រកម្ពុជា" និងអនុវត្តរួមគ្នា និងដោយឡែកទៅតាមមុខងាររៀងៗខ្លួន ក្នុងគោលដៅរួមគឺធ្វើឲ្យកម្ពុជាមានកំណើនសេដ្ឋកិច្ច និងសហគ្រាសមានចិរភាព។យើងត្រូវចងចាំទាំងអស់គ្នាថា ពាណិជ្ជកម្មជោគជ័យ កម្ពុជារុងរឿង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក** និងបងប្អូនទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ